Press release

# ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម យកចិត្តទុកដាក់អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

---

អនុវត្តតាមអនុសាសន៍ណែនាំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅព្រឹកថ្ងៃទី២៣ និង២៤ ខែសីហា ឆ្នាំ២០១៦ ក្រុមការងារសកម្មភាពជនពិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមសហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ បានបើកកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដល់មន្ត្រីរាជការនៃមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងអង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប។

ឯកឧត្តម អ៊ុំ សុថា អនុរដ្ឋលេខាធិការ និងជាអនុប្រធានក្រុមការងារសកម្មភាពជនពិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានដឹកនាំកិច្ចប្រជុំនេះ នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប បានបញ្ជាក់ឱ្យដឹងថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រោមការដឹកនាំរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** តែងបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ និងមានគោលការណ៍លើកទឹកចិត្តចំពោះជនពិការ ដោយក្នុងនោះ បានផ្តល់អាទិភាពក្នុងការជ្រើសរើសជនពិការ ឲ្យចូលបម្រើការងារក្នុងក្រសួង មន្ទីរ ជារៀងរាល់ឆ្នាំ បានដាក់ចេញនូវគោលការណ៍លើកទឹកចិត្តដល់មន្ត្រីរាជការជាជនពិការ ដូចជា ការផ្តល់មុខតំណែងសមស្របសម្រាប់ពួកគាត់ក្នុងតួនាទីដឹកនាំក្នុងអង្គភាព ការគាំទ្រជាស្មារតី ថវិកា ពេលមានធុរៈចាំបាច់ ការជួយបណ្តុះបណ្តាលសិក្សារៀនសូត្រ និងណែនាំដល់អង្គភាពនានា ត្រូវប្រកាន់ខ្ជាប់គោលការណ៍មិនរើសអើងជនពិការ។ ទន្ទឹមនឹងនេះ តាមរយៈការអនុវត្តតួនាទីរបស់ខ្លួន ក្រសួងនឹងជួយជំរុញឲ្យសហគ្រាសកម្មន្តសាល ជ្រើសរើសជនពិការឲ្យចូលបម្រើការងារតាមគ្រប់លទ្ធភាពដែលអាចធ្វើបាន និងបង្កលក្ខណៈងាយស្រួលដល់កម្មករ និយោជិតជាជនពិការក្នុងការបំពេញការងារ ស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានបង្កើតយន្តការសម្របសម្រួល អនុវត្តកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដោយបង្កើតក្រុមការងារសកម្មភាពជនពិការថ្នាក់ក្រសួង និងអនុក្រុមការងារសកម្មភាពជនពិការនៅថ្នាក់មន្ទីរផងដែរ ហើយបានចុះធ្វើសកម្មភាព និងរៀបចំរបាយការណ៍ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។

មានមតិក្នុងឱកាសនោះ លោកជំទាវ ប្រាក់ ថាវៈភារី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានយកចិត្តទុកដាក់សហការចូលរួមអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨។ លោកជំទាវរូបនេះ បានចាត់ទុកថា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាក្រសួងឈានមុខមួយ ដែលសកម្មក្នុងការចុះផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ដល់គ្រប់អង្គភាពក្រោមឱវាទនៅតាមមូលដ្ឋានរាជធានីខេត្ត។

គួរបញ្ជាក់ផងដែរថា ក្រុមប្រឹក្សាសកម្មភាពជនពិការបានបង្កើតឡើងកាលពីខែកក្កដា ឆ្នាំ២០០៩ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន និងមានក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធមួយចំនួនធំជាសមាជិក។





